00612999

F6/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 10 / 2010
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រ៊ឹម ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវុឌ្ឍ
ចៅក្រម Agnieszka KLONOWIECKAMILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម Chandra Nihal Jayasinghe
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំពន្យារកាលបរិច្ឆេទសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C

**សហមេធាវីការពារក្តីជនជាប់ចោទ**

ការ សាវុត្ថ

កង ឫទ្ធារី

**ជនជាប់ចោទ៖**

កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១**

ទី ស្រ៊ីនណា

Karim KHAN

Alain WERNER

Brianne McGONIGLE

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

Silke STUDZINSKY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣**

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN

Annie DELAHAIE

Philippe CANONNE

Elizabeth RABESANDRATANA

Fabienne TRUSSES-NAPROUS

Christine MARTINEAU



SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPRÊME F6/2

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “សំណើរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំពន្យារកាលបរិច្ឆេទ សម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០” (“សំណើសុំ”)[1] ។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ សហមេធាវីការពារក្ដី“ជនជាប់ចោទ” កាំង ហ្គេកអ៊ាវ *ហៅ* ឌុច បានដាក់“សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០” (“សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ”)[2] ។ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីការពារក្ដី បានដាក់សំណើសុំរបស់ខ្លួន។

២. នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ សហព្រះរាជអាជ្ញា បានដាក់“ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំបន្ថែមពេលវេលាដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន” (“ចម្លើយតប”)[3]។ អនុលោមទៅតាមមាត្រា ១០ នៃសេចក្ដីណែនាំ អនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខអ.វ.ត.ក(“សេចក្ដីណែនាំអនុវត្ត”)[4] ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល បានបញ្ជូនចម្លើយតបនេះត្រឡប់ទៅការិយាល័យសហព្រះរាជអាជ្ញាវិញ ពីព្រោះចម្លើយតបនេះ មិនបានគោរពទៅតាមមាត្រា៨(៣) និងមាត្រា៩ នៃសេចក្ដីណែនាំអនុវត្ត។ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ ការិយាល័យសហព្រះរាជអាជ្ញា បានដាក់ចម្លើយតបនេះមកកាន់ក្រឡាបញ្ជីដោយបញ្ជាក់ពីមូលហេតុនៃការយឺតយ៉ាវនេះផងដែរ[5]។

---

[1] នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០, F6។

[2] E188/8។

[3] នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០, F6។

[4] អ.វ.ត.ក/០១/២០០៧, F6។

[5] អនុលោមទៅតាម មាត្រា៩នៃសេចក្ដីណែនាំអនុវត្ត, ហេតុផលទាំងនេះ បានបញ្ចូលក្នុង “ទម្រង់សេចក្ដីណែនាំដាក់ឯកសារ”។ សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំពន្យារកាលបរិច្ឆេទ [illegible] សារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង [illegible] F6/2 ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០) ។

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

P6/2

## II. ផ្នែកសំអាងហេតុ

## ក. ច្បាប់ជាធរមាន

៣. វិធានផ្ទៃក្នុងដែលពាក់ព័ន្ធមានដូចខាងក្រោម៖

សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដូចមានចែងក្នុងវិធាន ១០៥(៣) ត្រូវធ្វើក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬ ការជូនដំណឹងអំពីសាលក្រមនោះ តាមករណីសមស្រប។ សារណាបណ្តឹងសាទុក្ខ ត្រូវដាក់ក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនេះតទៅ...

....

តាមរយៈការស្នើសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមការយល់ឃើញរបស់ខ្លួន អង្គជំនុំជម្រះអាច៖

(ក) ពន្យារកាលបរិច្ឆេទ ដែលខ្លួនបានកំណត់ទុក[6] ។

៤. ផ្នែកដែលពាក់ព័ន្ធនៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មានដូចខាងក្រោម៖

លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ឬ សេចក្តីណែនាំអនុវត្តនេះ ឬ បទបញ្ជាពីអង្គជំនុំជម្រះនៃអ.វ.ត.ក សារណា និងពាក្យសុំទាំងឡាយ ត្រូវដាក់នៅចំពោះមុខក្រឡាបញ្ជីនៃអង្គជំនុំជម្រះដែលជម្រះរឿងក្តីនេះ ដោយភ្ជាប់មកជាមួយបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ពាក់ព័ន្ធដែលប្រើប្រាស់ជាឯកសារយោង ដោយអនុលោមទៅតាមពេលវេលាកំណត់ដូចខាងក្រោម ហើយត្រូវបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន៣៩ នៃវិធានផ្ទៃក្នុង ប្រសិនបើមានការស្នើសុំពន្យារពេលកំណត់។

...

ចម្លើយតបណាមួយទៅនឹងសារណា ត្រូវដាក់ភ្ជាប់មកជាមួយបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃប្រតិទិន គិតចាប់ពីថ្ងៃជូនដំណឹងជាភាសាផ្លូវការរបស់អ.វ.ត.ក ដែល

[6] វិធាន ១០៧(៤), ៣៩.៤(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៦)
សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំពន្យារកាលបរិច្ឆេទសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង (... ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០) ។

SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPREME

ភាគីបានស្នើសុំ តាមមាត្រា២(២)អំពីឯកសារដែលអ្នកទាំងនោះត្រូវឆ្លើយតប។ ចម្លើយតបណាមួយទៅនឹងពាក្យសុំ ត្រូវដាក់ក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងតទៅ។

...

ឯកសារអាចដាក់ក្រោយរយៈពេលកំណត់ ដូចមានចែងនៅក្នុងវិធាន ៣៩ នៃវិធានផ្ទៃក្នុង។ នៅក្នុងករណីនេះ បុគ្គលដែលដាក់ឯកសារនេះ ត្រូវបញ្ជាក់អំពីមូលហេតុនៅក្នុងពាក្យសុំដាក់ឯកសារអំពីការយឺតយ៉ាវក្នុងការដាក់ឯកសារ។ ចៅក្រម ឬ អង្គជំនុំជម្រះដែលទទួលបានឯកសារនៅចំពោះមុខ ត្រូវសម្រេចថាទទួល ឬ មិនទទួលយកឯកសារនេះ ទោះបីជាឯកសារនេះ បានដាក់យឺតក៏ដោយ[7]។

## ខ. ការទទួលយកទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់

៥. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជនជាប់ចោទ គឺជា"ភាគីពាក់ព័ន្ធ" ដែលស្ថិតនៅក្នុងអត្ថន័យនៃវិធាន ៣៩.៤(ក)នៃវិធានផ្ទៃក្នុង។ សំណើសុំនេះ ត្រូវបានដាក់មុនកាលបរិច្ឆេទ នៃការដាក់សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ហើយសំណើនេះបានលើកឡើងអំពីមូលហេតុដែលគេត្រូវទទួលយក។ ហេតុដូច្នេះ សំណើសុំនេះ អាចទទួលយកបានដោយត្រឹមត្រូវតាមទម្រង់ច្បាប់។

៦. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សំណើនេះ គឺជា "ពាក្យសុំ" ដែលស្ថិតក្នុងអត្ថន័យនៃមាត្រា៨(៣)នៃសេចក្តីណែនាំអនុវត្ត។ ដូច្នេះ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងពាក្យសុំបានដាក់មកយឺត។ សហព្រះរាជអាជ្ញា បានលើកពីហេតុផលដែលបណ្តាលឲ្យយឺតយ៉ាវដូចខាងក្រោម៖

សហព្រះរាជអាជ្ញា មិនមានបំណងជំទាស់ទៅនឹងពាក្យសុំរបស់ឌុចនោះទេ។ ប៉ុន្តែ ខ្លួនមានបំណងធ្វើកំណត់ត្រានូវហេតុផលរបស់ខ្លួនតែប៉ុណ្ណោះ។ ការធ្វើដូច្នេះ អាចនឹងជាជំនួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការសម្រេចសេចក្តីមួយប្រកបដោយយុត្តិធម៌លើពាក្យសុំនេះ។ ដូច្នេះ ការ

[7] មាត្រា ៨(១), ៨(៣), ៩។

សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំពន្យារកាលបរិច្ឆេទសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ([illegible] ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០) ។

ទទួលយកចម្លើយតបនេះ ទោះបីជាហួសកំណត់កាលបរិច្ឆេទទៅតាមបទប្បញ្ញត្តិក៏ដោយ នឹងផ្តល់នូវអត្ថប្រយោជន៍នៃយុត្តធម៌[8]។

៧. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ហេតុផលទាំងនេះរបស់សហព្រះរាជអាជ្ញា មិនបានពន្យល់ពីមូលហេតុដែលយឺតយ៉ាវក្នុងការដាក់ចម្លើយតបនេះទេ។ អង្គជំនុំជម្រះពិចារណាឃើញថា ខ្លឹមសារនៃចម្លើយតបនេះ មិនបាន"ជាជំនួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយយុត្តិធម៌"លើសំណើនោះទេ។ ដូច្នេះ ចម្លើយតបនេះ មិនអាចទទួលយកបានទេ។

## គ. អង្គសេចក្តី

៨. សំណើនេះ បានស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូល ពន្យារកាលបរិច្ឆេទសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទរយៈពេល៣០ថ្ងៃទៀត[9]។ សហមេធាវីការពារក្តី បានផ្តល់ហេតុផលលើសំណើសុំនេះដូចខាងក្រោម៖

១. ទំហំ និងភាពស្មុគស្មាញនៃរឿងក្តីនេះ តម្រូវឱ្យមានការពន្យារពេលក្នុងការរៀបចំសារណាបណ្តឹងសាទុក្ខ ...

២. ... អង្គជំនុំជម្រះសាលាដំបូង បានធ្វើសេចក្តីប្រកាសថ្មីៗហើយប្លែកជាច្រើនទៅលើអង្គហេតុ និងអង្គច្បាប់។ ភាពថ្មីហើយប្លែកនៃសំណុំរឿងនេះ ដែលជារឿងក្តីដំបូងរបស់អ.វ.ត.ក បានបង្កឱ្យមានបញ្ហាប្រឈមដ៏ប្លែកដល់មេធាវីការពារក្តី...

៣. ការពន្យារពេលកំណត់ដើម្បីដាក់សារណារបស់មេធាវីការពារក្តី នឹងផ្តល់ជាវិធានការដំណោះស្រាយមួយចំនួនចំពោះវិសមភាពនៃមធ្យោបាយដែលមានចំពោះភាគីទាំងអស់ នៅក្នុងរឿងក្តីនេះ។ ក្រុមអ្នកច្បាប់របស់ជនជាប់ចោទ មានគ្នាតែបួននាក់ប៉ុណ្ណោះ ពោលគឺសហមេធាវីពីរនាក់

---

[8] សេចក្តីណែនាំដាក់ឯកសារ។

[9] សំណើ កថាខ័ណ្ឌ២,៤។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C F6/2

អ្នកគ្រប់គ្រងសំណុំរឿងម្នាក់ និងទីប្រឹក្សាផ្នែកច្បាប់ម្នាក់។ នៅអំឡុងពេលសវនាការកន្លងមក ការិយាល័យសហព្រះរាជអាជ្ញាមានក្រុមអ្នកច្បាប់ច្រើនជាងក្រុមមេធាវីការពារក្ដីរហូតទៅបីបួនដងឯណោះ។ ដូចគ្នានេះដែរ ចំនួនមេធាវីការពារក្ដីសម្រាប់ជនជាប់ចោទ ក៏ត្រូវមានចំនួនច្រើនផងដែរ នៅពេលត្រៀមរៀបចំការការពារក្ដីឲ្យជនជាប់ចោទ។ មេធាវីការពារក្ដី ក៏ត្រូវការពេលវេលាគ្រប់គ្រាន់ក្នុងការពិចារណាពីការចូលអន្តរាគមន៍ដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែលមានគ្នារហូតទៅដល់១៧នាក់...

៤. បន្ទាប់ពីការចេញសាលក្រមកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ភ្លាម ជនជាប់ចោទបានជ្រើសរើសលោកបណ្ឌិត កង ឫទ្ធារី ឲ្យធ្វើជាសហមេធាវីការពារក្ដីនៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន។ ក្នុងនាមជាមេធាវីដែលទើបតែតែងតាំងថ្មីម្នាក់ លោកបណ្ឌិត កង ឫទ្ធារី ត្រូវការពេលវេលាបន្ថែមទៀតដើម្បីពិនិត្យនីតិវិធីនៃការជំនុំជម្រះក្ដី និងសិក្សាពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង[10]។

៩. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មូលហេតុដែលបានលើកឡើងដោយសហមេធាវីការពារក្ដីក្នុងកថាខ័ណ្ឌទី៨(៣)ខាងលើ មិនបានបង្កើតជាហេតុផលដ៏ល្អ[11]សម្រាប់អង្គជំនុំជម្រះក្នុងការផ្ដល់ការអនុញ្ញាតដល់សំណើសុំនេះទេ។ តាមវិធានផ្ទៃក្នុង គេអាចបកស្រាយលើទំហំធនធានដែលសហព្រះរាជអាជ្ញាមាន ដោយផ្អែកលើការពិតថា ការិយាល័យសហព្រះរាជអាជ្ញា មានកាតព្វកិច្ចច្រើនជាងសហមេធាវីការពារក្ដីជនជាប់ចោទ។ ពាក់ព័ន្ធនឹងទំហំធនធានដែលជនជាប់ចោទមាន អង្គជំនុំជម្រះតុលាការកំពូលធ្វើការបញ្ជាក់ថា តាមការអនុវត្តសិទ្ធិជ្រើសរើសតំណាងរបស់ខ្លួន ជនជាប់ចោទ ត្រូវតែគិតអំពីភាពចាំបាច់ក្នុងការគោរពនូវកាលបរិច្ឆេទដើម្បីកុំឲ្យអូសបន្លាយនីតិវិធីឥតសមហេតុផល។

១០. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ហេតុផលដែលបានលើកឡើងខាងលើដោយសហមេធាវីការពារក្ដីក្នុងកថាខ័ណ្ឌ៨(១)(២)(៤) គឺជាហេតុផលមួយដ៏ល្អសម្រាប់អង្គជំនុំជម្រះធ្វើការ

---

[10] សំណើ កថាខ័ណ្ឌ៣(១)-(៤)។

[11] តុលាការព្រហ្មទណ្ឌអន្តរជាតិ, បទប្បញ្ញត្តិរបស់តុលាការ, ICC-BD/01-02-07, ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ (ត្រូវបានកែប្រែ), បទប្បញ្ញត្តិ៣៥(២)។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

ពន្យារពេលត្រឹម៣០ថ្ងៃ សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ។ ហេតុដូច្នេះ សំណើសុំ ត្រូវបានអនុញ្ញាត។ សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ត្រូវតែដាក់នៅក្នុងរយៈពេល៩០ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ជនជាប់ចោទនេះតទៅ។

## III. ផ្នែកសម្រេចសេចក្តី

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជាឯកច្ឆន្ទ៖**

១. ទទួលយកសំណើសុំទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២. បដិសេធចម្លើយតប។

៣. អនុញ្ញាតតាមសំណើសុំ។

**រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

SUPREME COURT CHAMBER E.C.C.C * C.E.T.C CHAMBRE DE LA COUR SUPRÊME

**គង់ ស្រ៊ឹម**